


Published on Phnom Penh (http://www.phnompenh.gov.kh/phnompenh)



# គម្រោង ប្លង់គោល រាជធានី ភ្នំពេញ

By admin
បាន បង្កើត 2009-03-07 19:29

គម្រោង ប្លង់ គោល រាជធានី ភ្នំពេញ
"យុទ្ធសាស្ត្រ តម្រង់ ទិស"



## ប្រវត្តិ នៃ ការ រៀបចំ ប្លង់ គោល ភ្នំពេញ

- យោង តាម ការ ស្រាវជ្រាវ មាន តែ ប្លង់ គោល ឆ្នាំ ១៩៥០ មួយ គត់ ដែល បាន អនុម័ត ជា ផ្លូវការ ដោយ ក្រសួង កសិកម្ម នៅ ថ្ងៃ ទី ០៦ ខែ មេសា ឆ្នាំ ១៩៥០ ដែល ធ្វើ ឡើង ដោយ ការិយាល័យ សិក្សា គម្រោង របស់ លោក Chauchon ។

- ប្លង់ គោល នា ពេល នោះ ជា ប្លង់ តម្រង់ ទិស អភិវឌ្ឍន៍ តំបន់ ធំៗ ដូចជា ៖ ពហុកីឡាដ្ឋាន អូឡាំពិក និង តំបន់ លំនៅឋាន ជុំវិញ, តំបន់ ទួលគោក តំបន់ បុរី កីឡា, តំបន់ សកលវិទ្យាល័យ ភ្នំពេញ...
- ឆ្នាំ ១៩៧០ មាន ការិយាល័យ នគរោបនីយកម្ម ដឹកនាំ ដោយ លោក លុយ បាន ហាប់ ក៏ មាន បំណាង រៀបចំ កែប្រែ និង ពង្រីក ទីក្រុង ភ្នំពេញ បន្ថែម ទៀត ប៉ុន្តែ មិន បាន សម្រេច ។
- ឆ្នាំ ១៩៩៣ មាន ការ សិក្សា ជា ឯកសារ គោល របស់ លោក Guy Lemarchand ស្ដី ពី គម្រោង ប្លង់ គោល ទីក្រុង ភ្នំពេញ ធំ (Greater Phnom Penh) ។
- ឆ្នាំ ២០០២-២០០៥ គម្រោង ប្លង់ គោល រាជធានី ភ្នំពេញ ក្រោម កម្មវិធី FSP របស់ សាធារណរដ្ឋ បារាំង ។

## និយមន័យ នៃ ប្លង់ គោល

ប្លង់ គោល ជា ឯកសារ មាន លក្ខណៈ យុទ្ធសាស្ត្រ នៃ ការរៀបចំ អភិវឌ្ឍន៍ ទីក្រុង រហូត ដល់ ២០២០ ។

- ផែនទី នៃ ប្លង់គោល នេះ នឹង រៀបចំ ក្នុង មាត្រដ្ឋាន ១/២៥.០០០ ។
- ប្លង់គោល នេះ មាន ទិសដៅ កំណត់ ដូច ខាងក្រោម ៖

+ កំណត់ តំបន់ ដែល ជា ដី សាធារណៈ របស់ រដ្ឋ និង តំបន់ ហាម សាងសង់ ព្រមទាំង តំបន់ ផ្សេង ទៀត ដែល ប្រើប្រាស់ ជា រួម ឬ បម្រុង ទុក ជា សម្បត្តិ រដ្ឋ និង លំហ នានា ដូចជា លំហ កម្ពស់ សម្រាប់ យន្តហោះ ចុះ ឡើង ផែ និង បរិក្ខារ សាធារណៈ ធំៗ ផ្សេង ទៀត
+ បង្កើត អនុសាសន៍ ដែល ជា យុទ្ធសាស្ត្រ អភិវឌ្ឍន៍ សេដ្ឋកិច្ច និង សង្គមកិច្ច របស់ ទីក្រុង ។

បំណាង នេះ គឺ សំដៅ រៀបចំ តម្រង់ ទិស សម្រាប់ ថ្ងៃ អនាគត នូវ ការ វិនិយោគ របស់ រដ្ឋ និង ឯកជន ។

## គម្រោង ដែល មិន រាប់ បញ្ចូល ក្នុង ប្លង់គោល

- ប្លង់ ដែល អាច ជា នគរោបនីយបញ្ញត្តិ ៖ ប្លង់ កម្ពស់, ប្លង់ ជួរ តម្រង់, ប្លង់ គម្លាត សាធារណៈ,ប្លង់ លំហ បៃតង, ប្លង់ ការពារ បេតិកភណ្ឌ, ប្លង់ បែងចែក តំបន់, ប្លង់ ការពារ ភាព រំខាន ដោយ សំឡេង, ប្លង់ តំបន់ ហាម សាងសង់...
- ប្លង់ អភិវឌ្ឍន៍ តំបន់ ៖ ប្លង់ អភិវឌ្ឍន៍ ទេសចរណ៍,ប្លង់ លំអិត អភិវឌ្ឍន៍ ឧស្សាហកម្ម, លំនៅឋាន
- ប្លង់គោល តាម វិស័យ នានា ៖ ប្លង់ គោល គមនាគមន៍, ប្លង់គោល ទឹក ស្អាត, ប្លង់គោល អគ្គិសនី, ប្លង់គោល បណ្ដាញ លូ...

ប្លង់ ទាំងអស់ ខាងលើ ត្រូវ រៀបចំ ឡើង ដោយ មន្ទីរ ដែនដី នគរោបនីយកម្ម និង សំណង់ ភ្នំពេញ ដោយ ផ្អែក លើ ប្លង់គោល នេះ ។

## នីតិវិធី រៀបចំ គម្រោង ប្លង់គោល ជំហាន ទី១ (សិក្សា)

- ការ ចងក្រង សៀវភៅ (ការ សិក្សា ស្រាវជ្រាវ-វិភាគ និង ព្យាករណ៍)

- ចក្ខុវិស័យ និង យុទ្ធសាស្ត្រ សម្រាប់ ឆ្នាំ ២០២០
- អនុក្រឹត្យ និង ផែនទី ក្នុង មាត្រដ្ឋាន ១/២៥.០០០
- យុទ្ធសាស្ត្រ តម្រង់ ទិស អភិវឌ្ឍន៍ (គម្រោង ព្រាង ប្លង់គោល នគរោបនីយកម្ម) ដើម្បី សុំ មតិ ពី រាជធានី ភ្នំពេញ និង ក្រសួងមហាផ្ទៃ ។
- យុទ្ធសាស្ត្រ តម្រង់ ទិស អភិវឌ្ឍន៍ (គម្រោង ព្រាង ប្លង់គោល នគរោបនីយកម្ម) ដើម្បី សុំ មតិ ពី ក្រសួង រៀបចំ ដែនដី នគរោបនីយកម្ម និង សំណង់ ជាមុន មុន នឹង បញ្ជូន ទៅ ទីស្តីការ គណៈរដ្ឋមន្ត្រី ដើម្បី សុំ ការ អនុមតិ ពី រាជរដ្ឋាភិបាល ដោយ បង្កើត ជា អនុក្រឹត្យ ។

**នីតិវិធី រៀបចំ គម្រោង ប្លង់គោល ជំហាន ទី២ (អនុម័ត)**

- ប្លង់គោល នគរោបនីយកម្ម រាជធានី ភ្នំពេញ ២០២០
- ផែនការ នៃ ដំណាក់កាល និង កម្មវិធី រៀបចំ អភិវឌ្ឍន៍ បន្តបន្ទាប់ (ផែនការ អភិវឌ្ឍន៍ រយៈពេល បន្ទាន់-រយៈពេល មធ្យម និង រយៈពេល វែង) ជំហាន ទី៣ (អនុវត្តន៍ គម្រោង)
- ផែនការ អភិវឌ្ឍន៍ ប្រចាំ ឆ្នាំ និង ថវិកា ចាំបាច់ ដើម្បី ការ អភិវឌ្ឍន៍ ទីក្រុង
- បទបញ្ញត្តិ និង ប្លង់ ប្រើប្រាស់ ដី ធ្លី នៃ ខណ្ឌ និង សង្កាត់

**ការសិក្សា នានា ដើម្បី រៀបចំ គម្រោង ប្លង់ គោល**

- ការ សិក្សា អំពី ប្រជាសាស្ត្រ សេដ្ឋកិច្ច-សង្គមកិច្ច
-ការសិក្សា អំពី ការ គ្រប់គ្រង ហិរញ្ញវត្ថុ និង រដ្ឋបាល ទីក្រុង
- ការសិក្សា អំពី ប្រព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធ និង បណ្តាញ គមនាគមន៍
- ការសិក្សា អំពី ប្រព័ន្ធ ធារាសាស្ត្រ ទីក្រុង
- ការសិក្សា អំពី ប្រភេទ នៃ ការ ប្រើប្រាស់ ដីធ្លី និង ទីផ្សារ ដីធ្លី និង លំនៅឋាន
- ការសិក្សា អំពី ប្រព័ន្ធ បៃតង និង ទេសភាព ទីក្រុង
- ការសិក្សា អំពី រូបសាស្ត្រ នៃ ការ វិវត្តន៍ នគរោបនីយកម្ម និង សំណង់
- ការសិក្សា អំពី បេតិកភណ្ឌ ប្រវត្តិសាស្ត្រ រាជធានី ភ្នំពេញ
- ការសិក្សា អំពី លទ្ធភាព អភិវឌ្ឍន៍ ប្រកួត ប្រជែង ជាមួយ ទីក្រុង នានា ក្នុង តំបន់ អាស៊ាន

**សិក្ខា សាលា ដែល បាន រៀបចំ នៅ រាជធានី ភ្នំពេញ កន្លង មក**

២២-មករា-០៤- ប្រព័ន្ធ បៃតង កសិកម្ម ទីក្រុង និង ទេសភាព ទីក្រុង
២៩-មករា-០៤- បេតិកភណ្ឌ ប្រវត្តិសាស្ត្រ រាជធានី ភ្នំពេញ
០៥-កុម្ភៈ-០៤- បណ្តាញ គមនាគមន៍ និង ការ ដឹក ជញ្ជូន ទីក្រុង
១២-កុម្ភៈ-០៤- សៀវភៅ និង ការ វិភាគ ទិន្នន័យ
១៩-កុម្ភៈ-០៤- ទីផ្សារ ដីធ្លី និង អចលនវត្ថុ ទីក្រុង
១៨-មិនា-០៤- សេដ្ឋកិច្ច ទីក្រុង និង ការ វិនិយោគ
០១-មេសា-០៤- បណ្តាញ លូ ទីក្រុង

០៨-មេសា-០៩- ការគ្រប់គ្រង សេវាកម្ម ទីក្រុង៖ ទឹក ស្អាត ទឹក សំអុយ និង សំរាម
១២-ឧសភា-០៩- ការ លើក តម្លៃ ទី កណ្តាល ក្រុង
១៩-ឧសភា-០៩- ការ ប្រកួតប្រជែង អន្តរជាតិ គម្រោង អភិវឌ្ឍន៍ បឹងកក់
១១-មិថុនា-០៩- គម្រោង ប្រព័ន្ធ ផ្លូវ ទីក្រុង
១៧-មិថុនា-០៩- ថវិកា និង ពន្ធដារ ទីក្រុង, ការ ផ្តល់ ហិរញ្ញវត្ថុ សម្រាប់ ការ កសាង ប្រព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធ ទីក្រុង
១៧-មិថុនា-០៩- គម្រោង ប្លង់ មេ សមស្រប សម្រាប់ ទីក្រុង
៣០-មិថុនា-០៩- ភ្នំពេញ ២០២០
១២-កក្កដា-០៩- ប្រព័ន្ធ ផ្លូវ មេ ទីក្រុង
២៨-កក្កដា-០៩- ភ្លៀង និង អាង ស្តុក ទឹក ភ្លៀង នៅ រាជធានី ភ្នំពេញ
២៩-កក្កដា-០៩- គណៈកម្មការ គម្រោង ប្រព័ន្ធ ធារាសាស្ត្រ ពោធិចិនតុង
០២-សីហា-០៩- ការ កំណត់ អាង ស្តុក ទឹក ភ្លៀង ក្នុង ទីក្រុង៖ បឹងសាឡាង-ក្រពើ-ទំពុន
១៥-កញ្ញា-០៩- ការ កំណត់ អាង ស្តុក ទឹក នៃ បណ្តាញ បឹង ខាងជើង រាជធានី ភ្នំពេញ
០៦-តុលា-០៩- គម្រោង ព្រាង ប្លង់ មេ ទីក្រុង ភ្នំពេញ សម្រាប់ ២០២០
១៩-តុលា-០៩- ការ តម្រង់ ទិស ជា យុទ្ធសាស្ត្រ សម្រាប់ ការអភិវឌ្ឍន៍ ទីក្រុង ភ្នំពេញ ២០២០

## ការ វិភាគ សេដ្ឋកិច្ច-សង្គមកិច្ច

**ភ្នំពេញ ក្នុង តំបន់ អាស៊ីអាគ្នេយ៍**

- រាជធានី មួយ នៅ អាស៊ីអាគ្នេយ៍
- ជា ទីក្រុង ទី ៣១៩ នៃ ពិភពលោក ផ្នែក ចំនួន ប្រជាជន (១,៣លាន នាក់)
- កំណើន ផលិតផល ជាតិ ៨៣០ដុល្លា/ឆ្នាំ តិច ជាង ៨០ដង នៃ ទីក្រុង បាងកក និង សិង្ហបុរី
- ស្ថិត ក្នុង ប្រព័ន្ធ ផ្លូវ សេដ្ឋកិច្ច អាស៊ាន(បាងកក-ហូជីមិញ )




Figure 2-8 Conceptual Image of Inland Network in Indochina

ប្រជាជន និង សេដ្ឋកិច្ច
- ទីក្រុង ដែល មាន ប្រជាជន ជាង មួយ លាននាក់ (១,៣លាន នាក់)
- កំណើន ប្រជាជន ខ្ពស់ = ៣.២%/ឆ្នាំ =៤០.០០០នាក់/ឆ្នាំ ( ១/៣ ជា ប្រជាជន ក្រីក្រ )
- ផលទុន ជាតិ សរុប ក្នុង ស្រុក ១,៣ពាន់ លាន ដុល្លារ នៅ ឆ្នាំ ២០០៣ =២៨ %នៃ ផលទុន ជាតិ សរុប
- ចលករ សេដ្ឋកិច្ច ៖
+ចំនួន ការងារ ៤៥០.០០០ (៨៦%ឧស្សាហកម្ម និង ៣៨% សេវាកម្ម)
+ប្រជាជន សកម្ម ៧០០.០០០ នាក់
- ពាណិជ្ជកម្ម ៖
+ស្តង់ លក់ដូរ មាន ចំនួន ២៥.០០០ ស្តង់
+ គ្រឹះស្ថាន ពាណិជ្ជកម្ម ១២.០០០ ដែល ចុះបញ្ជី
- វិនិយោគ ៖ ៣/៤ វិនិយោគទុន ឧស្សាហកម្ម នៃ ប្រទេស
- វិស័យ ដឹក ជញ្ជូន ៖ ៣/៤ នៃ ការ ដឹកជញ្ជូន នៃ ប្រទេស
- វិស័យ ទេសចរណ៍ ៖ ៩៥០.០០០នាក់ / ឆ្នាំ
- វិស័យ អប់រំ ៖ និស្សិត ២១.០០០នាក់, ១/៣ នៅ សកលវិទ្យាល័យ សាធារណៈ




| Métropole , Agglomération , Municipalité 2000 – 2020 Source : Institut National de la Statistique ( INS ) , JICA and BAU | | | |
|---|---|---|---|
| Population | Municipalité source : INS | Agglomaration Source : INS | Métropole Source : JICA+BAU |
| 1998 | 1039607 | 1077853 | 1333992 |
| 2000 | 1114479 | 1165244 | 1430066 |
| 2005 | 1313851 | 1403712 | 1685894 |
| 2010 | 1529301 | 1670230 | 1962353 |
| 2015 | 1753840 | 1958914 | 2250475 |
| 2020 | 1983104 | 2266289 | 2544659 |

Municipalité- គិត ត្រឹម ព្រំ ប្រទល់ រដ្ឋបាល នៃ ក្រុង ក្នុង ផ្ទៃ ក្រឡា ៣៧៥ គម$^2$ ។

Agglomération - គិត បញ្ចូល នូវ ទីប្រជុំជន ជាយក្រុង និង ជាប់ ជាយក្រុង ។

Métropole - គិត រួម ទាំង ប្រជាជន ៣០%នៃ ខេត្ត កណ្តាល ដែល ទទួល ផលប្រយោជន៍ ពី ភ្នំពេញ ។

ការ ប្រើប្រាស់ ដីធ្លី បច្ចុប្បន្ន
ភ្នំពេញ មាន ផ្ទៃក្រឡា ៣៧.៥០០ហាត ៖

- ៨០% ជា បឹង ធម្មជាតិ និង ដី ស្រែ កសិកម្ម (៥%ជាទន្លេ, ២៥%ដីលិចទឹក, ៥០%ជា ដី កសិកម្ម )
- ២០%ជា ដី សាងសង់ (១៦,៥%ក្នុង ទីក្រុង, ៣,៥%នៅ ជាយក្រុង)
- តំបន់ ក្នុង ក្រុង មាន ៦២០០ហាត់ ចែក ជា ៖
- ១/៣ ជា ដី គ្មាន សំណង់ ជា ផ្ទៃ ទឹក និង ព្រលានយន្តហោះ
- ២/៣ ជា ដី សាងសង់(រាប់ បញ្ចូល ទាំង ផ្លូវ)

- ដង់ស៊ីតេ មធ្យម ១៣០នាក់/ហាត (៥០០ន/ហាត នៅ កណ្តាល ក្រុង និង ៥០ន/ហាត នៅ ជាយក្រុង)



បណ្តាញ សេដ្ឋកិច្ច

បណ្តាញ សេដ្ឋកិច្ច ពីរ ៖

- ច្រក របៀង អភិវឌ្ឍន៍ សេដ្ឋកិច្ច ៖ បាងកក-ដី សណ្ដ មេគង្គ ( RN5/RN1-RN6 ផ្លូវដែក,ផ្លូវទឹក )
- ច្រក របៀង អភិវឌ្ឍន៍ សេដ្ឋកិច្ច ភ្នំពេញ-ក្រុង ព្រះសីហនុ ៖ ( RN5/RN1-RN6 ផ្លូវដែក )



## ភ្នំពេញ ជា មជ្ឈមណ្ឌល សេវាកម្មសម្រាប់ បម្រើ ប្រជាជន៦ លាន នាក់

- បច្ចុប្បន្ន ប្រជាជន ៦ លាន នាក់ទទួលបាន នូវ សេវាកម្ម ពី រាជធានី ភ្នំពេញក្នុង កម្រិតចម្ងាយ កាំ រង្វង់ ១០០ គីឡូម៉ែត្រ ជុំ វិញ ។
- ២០ ឆ្នាំ ទៅ មុខ ចំនួន ប្រជាជន ដែល ទទួលបាន សេវាកម្ម នេះ នឹង កើន ដល់ ១១ លាន នាក់
- ត្រូវ តែ ជំរុញ ការ អភិវឌ្ឍន៍ ទូទាំង ប្រទេសជា ពិសេស ទីក្រុង ធំ បន្ទាប់ដើម្បី ឱ្យ ការ អភិវឌ្ឍន៍មាន លំនឹងនិង តុល្យភាព ជាមួយ គ្នា ។
- ការ អភិវឌ្ឍន៍ ទីក្រុង ជាយដែន ព្រំប្រទល់







## សេណារីយ៉ូ អភិវឌ្ឍន៍

Scénarios de croissance économique

| | | 2002 | 2020 | | | | |
|---|---|---|---|---|---|---|---|
| | | | *Tendanciel* | *Text+serv* | *Crise* | *Services* | *Alter+Serv* |
| **Population** | *milliers* | 1 192 | 1 983 | 2 275 | 1 645 | 2 203 | 1 983 |
| *Croissance démographique* | | *4.5%* | *2.9%* | *3.7%* | *1.8%* | *3.5%* | *2.9%* |
| ***Population active*** | *milliers* | 784 | 1 785 | 2 047 | 1 480 | 1 983 | 1 785 |
| *Croissance* | | *5.2%* | *4.7%* | *5.5%* | *3.6%* | *5.3%* | *4.7%* |
| **PIB** | M.USD | 1 146 | 2 912 | 4 497 | 1 823 | 3 408 | 4 845 |
| *Croissance* | | *10.7%* | *5.3%* | *7.9%* | *2.6%* | *6.2%* | *8.3%* |
| ***Structure secteur formel*** | | | | | | | |
| Agriculture | | 4% | 1% | 1% | 1% | 1% | 0% |
| Industrie | | 36% | 53% | 34% | 25% | 13% | 21% |
| Services | | 60% | 46% | 65% | 74% | 86% | 78% |
| **Emploi** | *milliers* | 706 | 1 107 | 1 270 | 1 020 | 1 230 | 1 230 |
| *Croissance de l'emploi* | | *23.5%* | *2.5%* | *3.3%* | *2.1%* | *3.1%* | *3.1%* |
| ***Structure secteur formel*** | | | | | | | |
| Agriculture | | 7% | 1% | 1% | 2% | 1% | 1% |
| Industrie | | 36% | 53% | 30% | 21% | 12% | 29% |
| Services | | 57% | 46% | 70% | 77% | 87% | 71% |
| **Taux d'emplois informels** | | **28%** | **23%** | **10%** | **54%** | **20%** | **10%** |
| **PIB/habitant** | USD | 1 110 | 1 583 | 1 905 | 1 108 | 1 636 | 2 209 |
| *Croissance* | | *1.5%* | *2.0%* | *3.0%* | *0.0%* | *2.2%* | *3.9%* |
| **Revenu/habitant** | USD | 412 | 669 | 979 | 457 | 767 | 1 006 |
| *Croissance* | | | *2.7%* | *4.9%* | *0.6%* | *3.5%* | *5.1%* |
| **Investissement annuel (m** | M.USD | | 290 | 1 158 | 240 | 922 | 1 391 |
| ***Structure*** | | | | | | | |
| Agriculture | | | 0% | 0% | 0% | 0% | 0% |
| Industrie | | | 30% | 5% | 15% | 4% | 19% |
| Services | | | 70% | 95% | 85% | 96% | 81% |
| | | | *Essoufflement* | *Décollage* | *Récession* | *Services* | *Mutation* |




ប្រាក់ ចំណូល សម្រាប់ ម្នាក់ៗ




## ប្រព័ន្ធ គមនាគមន៍ ដឹកជញ្ជូន៖ការ តភ្ជាប់ ទៅ នឹង បណ្តាញ គមនាគមន៍ ពិភពលោក និង ក្នុង តំបន់

- ព្រលានយន្តហោះ
- ផែ
- ផ្លូវគោក និង ផ្លូវដែក

ព្រលានយន្តហោះ អន្តរជាតិ ភ្នំពេញ

- អាកាសយានដ្ឋាន តូច(ភ្ញៀវ ១លាន នាក់/ឆ្នាំ) បើ ប្រៀបធៀប នឹង បណ្តា អាកាសយានដ្ឋាន អន្តរជាតិ ក្នុង តំបន់ ។
- សម្រាប់ ៥០ ឆ្នាំ ទៅ មុខ អាច កើន ដល់ ៥ លាន នាក់/ឆ្នាំ (កំណើន ពី ៥ទៅ៧%) ។
- មាន ទីតាំង នៅ ជិត ក្រុង និង ក្បែរ តំបន់ ឧស្សាហកម្ម
- មាន ការ រៀបចំ បម្រុង ទុក នូវ ផែ ទំនិញ ឃ្លាំង ចំណត និង បរិក្ខារ សុវត្ថិភាព ហោះហើរ ។
- អាច ប្រើប្រាស់ បាន យ៉ាង ពេញ សមត្ថភាព ដល់ ឆ្នាំ ២០២០ ។










**ផែ និង គមនាគមន៍ ផ្លូវ ទឹក**

- ផែ ក្រុងព្រះសីហនុ មាន ទំហំ តូច ប្រៀបធៀប មាត្រដ្ឋាន តំបន់(១%នៃ សិង្ហបុរី) ប៉ុន្តែ ជា ច្រក ទ្វារ សំខាន់ សម្រាប់ ប្រទេស កម្ពុជា ។
- ផែ ក្រុង ភ្នំពេញ ៖ គួរ រក្សា និង កែលំអ ពង្រីក -ផែ ជំនួយ នៃ ផែ ព្រះសីហនុ
- ផែ ក្នុង ទីក្រុង ៖ មាន ភាព ងាយស្រួល ព្រោះ ជិត អ្នក ផលិត/អ្នកប្រើប្រាស់
- ទន្លេ មេគង្គ ៖ មាន សក្តានុពល ច្រើន អាច ទទួល កប៉ាល់ ផុន ៣០០០-៥០០០ តោន

- ត្រូវការ ពង្រីក ផ្ទែ ស្តុក ទំនិញ ឃ្លាំង កែលំអ បរិក្ខារ
- ចំណុច គ្រោះថ្នាក់ ៖ ឃ្លាំង ប្រេង នៅ ទន្លេសាប









ប្រព័ន្ធ ផ្លូវ ដែក

- បណ្តាញ ផ្លូវ ដែក នៃ កម្ពុជា ភ្ជាប់ ពី ភ្នំពេញ ទៅ ក្រុងព្រះសីហនុ និង ព្រំ ប្រទល់ ថៃ
- ការ ជួសជុល ផ្លូវដែក និង ក្បាលរថភ្លើង មាន ការ យឺតយ៉ាវ ដំណើរការ សេដ្ឋកិច្ច ខ្សោយ ។
- បរិមាណ ដឹក អ្នកដំណើរ ថយ ចុះ ។ រី ឯ បរិមាណ នៃ ការ ដឹកទំនិញ កើន ឡើង ។
- តម្រូវការ ចាំបាច់ ធានា សុវត្ថិភាព ចរាចរ និង ល្បឿន ពាណិជ្ជកម្ម ត្រឹមត្រូវ ។



ចរាចរ ផ្លូវ ដែក កម្ពុជា




ប្រព័ន្ធ ផ្លូវ និង ផែ ស្ងួត

- ផែ ស្ងួត នៅ តំបន់ ត្រីកោណ
- ស្ថានីយ សំរោង ជា កន្លែង ស្តុក, ច្រក ល្បៀង សេដ្ឋកិច្ច រាជធានី ភ្នំពេញ
- កំពុង ផែ ជាតិ ក្រុងព្រះសីហនុ
- តំបន់ ផ្លាស់ប្តូរ សេដ្ឋកិច្ច អន្តរ តំបន់
- ផែ ស្ងួត បន្ទាប់ នៅ គ្រប់ ច្រក ចូល ទីក្រុង
- ភ្ជាប់ រាជធានី ភ្នំពេញ ទៅ នឹង បណ្តា ទីក្រុង នានា ក្នុង តំបន់






## ការ រៀបចំ លំហ ទីក្រុង-បៃងចៃក តំបន់

បេតិកភណ្ឌ និង ទេសភាព ទីក្រុង

- រក្សា និង អភិរក្ស រមណីយដ្ឋាន ចតុមុខ
- រក្សា តំបន់ ដូនពេញ ជា មជ្ឈមណ្ឌល ប្រវត្តិសាស្ត្រ និង បេតិកភណ្ឌ ជាតិ ។
- បង្កើន ការ ដាំ ដើមឈើ ក្នុង រាជធានី ភ្នំពេញ
- បង្កើន ក្រឡា ផ្ទៃ បៃតង ក្នុង តំបន់ សំណង់ ណែន
- រក្សា ក្រវាត់ បៃតង និង ភូមិ ប្រពៃណី នៅ ជាយក្រុង
- រក្សា និង ដាំ ដើម តាម ប្រឡាយ មាត់បឹង ទន្លេ
- រៀបចំ អភិវឌ្ឍន៍ ទីក្រុង ដោយ បន្ត ប្រពៃណី បៃតង




ត្រូវ រៀបចំ ទីប្រជុំជន បន្ទាប់ នៅជុំវិញ ទីក្រុង គឺ នៅ តាម ច្រក ចូលរាជធានី អាច ជា ទីប្រជុំជន រណប

-ចោមចៅ
-សំរោង
-ជ្រោយចង្វារ
-ព្រែកព្នៅ
-តាខ្មៅ
-ច្បារអំពៅ ។ល។




ទីប្រជុំជន បន្ទាប់ អនាគត

បណ្តាញ បឹង

បឹង ខាងជើង ៖ បឹង ប៉ាយ៉ាប បឹង ពោងពាយ បឹង រាជសី បឹង ក្បាលដំរី បឹង ស្ទឹងកំបុត...

- ជា អាង ស្តុក ទឹក បម្រើ ដល់ ការ អភិវឌ្ឍន៍ តំបន់ លំនៅឋាន ប្រណិត និង ទីប្រជុំជន ថ្មី ។

- ផ្ទៃ បឹង ត្រូវ ថែរក្សា
បឹង ខាងត្បូង៖ បឹងទំពុន បឹង ជើងឯក
- អាង ស្តុក ទឹក ចុងក្រោយ និង ជា កន្លែង ច្រោះ ទឹក ស្អុយ ។
- ផ្ទៃ បឹង ត្រូវ រក្សាទុក បឹង ជើងឯក




នយោបាយ លំនៅឋាន

ដោយ កំណើន ប្រជាជន រាជធានី ភ្នំពេញ ខ្លាំង និង ត្រូវការ ប្រមាណ ជិត ១ ម៉ឺន លំនៅឋាន/ឆ្នាំ ចំណុច ៥ យ៉ាង ដែល ត្រូវ គិតគូរ គឺ៖

១-ជំរុញ ការ វិនិយោគ ផ្នែក លំនៅឋាន និង ដីធ្លី សម្រាប់ ប្រជាជន គ្រប់ ស្រទាប់

២-រៀបចំ អភិវឌ្ឍន៍ ប្រព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធ គ្រប់បែប យ៉ាង នៅ តំបន់ ជាយក្រុង ដែល អាច ស្រូប ទទួល យក ៩០%នៃ កំណើន ប្រជាជន រហូត ដល់ ឆ្នាំ ២០២០ ។

៣-អនុវត្ត នយោបាយ សម្បទាន ដី សង្គមកិច្ច នយោបាយ ចែក រំលែក ដីធ្លី ការ ផ្លាស់ទី លំនៅ ទៅ តំបន់ ថ្មី ដោយ មានការ ចូលរួម ពី ឯកជន ។

៤- ជំរុញ ឱ្យ មាន ការ វិនិយោគ អភិវឌ្ឍន៍ លំនៅឋាន ជួល នៅ រាជធានី

៥-លើក ទឹកចិត្ត ការ ជួសជុល អគារ ស្នាក់ នៅ រួម ដែល ជា អគារ ចាស់ៗ ដោយ ខ្ចី ប្រាក់ ដែល មាន ការ ប្រាក់ ទាប ។

## យុទ្ធសាស្ត្រ តម្រង់ ទិស អភិវឌ្ឍន៍

ការ តម្រង់ ទិស នៃ គម្រោង ប្លង់មេ

១- ភ្នំពេញ មាន មុខងារ មួយ ច្បាស់លាស់ គឺ ទីក្រុង រាជធានី ទីក្រុង រដ្ឋបាល សេដ្ឋកិច្ច វប្បធម៌ និង

ទេសចរណ៍ ។




២- កំណត់ ជា អតិបរមា នូវ ប្រព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធ ធំៗ មាន ស្រាប់ ដូចជា៖

គម្រោង ពង្រីក ព្រលានយន្តហោះ គម្រោង ពង្រីក ផែ គម្រោង បង្កើត ស្ថានីយ រថភ្លើង ថ្មី នៅ ជាយក្រុង(ស្ថានីយ សំរោង) និង ផែ ស្ទួត ការ កែ លំអ រៀបចំ ស្ថានីយ រថភ្លើង ចាស់ នៅ ភ្នំពេញ និង ការ បង្កើត ឱ្យ មាន ប្រព័ន្ធ ដឹក ជញ្ជូន រួម ផ្លូវដែក ទៅ តំបន់ ខាងជើង(ឫស្សីកែវ) និង ខាងលិច ទីក្រុង ភ្នំពេញ(ដង្កោ)

៣- កំណត់ ព្រំប្រទល់ ដី សាធារណៈ (បឹង ប្រឡាយ ផ្លូវថ្នល់ ផ្លូវដែក ព្រលានយន្តហោះ ផែ និង តំបន់ បរិស្ថាន បៃតង)។



៤- រៀបចំ តំបន់ សម្រាប់ ទទួល ការអភិវឌ្ឍន៍ សេដ្ឋកិច្ច៖ ការ រៀបចំ ប្រព័ន្ធ និង បណ្ដាញ ផ្លូវ ដើម្បី ការ អភិវឌ្ឍន៍ ដី ធ្លី និង លំនៅឋាន នៅ ជាយក្រុង ។

៥- រៀបចំ តំបន់ សម្រាប់ ទទួល និង ស្រូប យក កំណើន ប្រជាជន ជា ពិសេស គ្រួសារ ក្រីក្រ ដែល ត្រូវ រស់នៅ ក្បែរ កន្លែង ដែល មាន ការងារ ធ្វើ ។




៦- រៀបចំ ពង្រីក ព្រំប្រទល់ រាជធានី ភ្នំពេញ ក្នុង កាំ រង្វង់ ៣០គម ជុំវិញ ចំណុច កណ្តាល វត្តភ្នំ និង បង្កើត ខណ្ឌ អរិយក្សត្រ ថ្មី មួយ បញ្ចូល មក ក្នុង រាជធានី ភ្នំពេញ។ ខណ្ឌ ថ្មី នេះ នឹង គ្រោង ទុក សម្រាប់ ការ អភិវឌ្ឍន៍ រយ:ពេល វែង ។

៧- រៀបចំ កិច្ចសហការ រួម ជាមួយ គ្រប់ ដៃ គូ អភិវឌ្ឍន៍ ដូចជា៖ អ្នក វិនិយោគ ឯកជន ធនាគារ ក្រុមហ៊ុន ដីធ្លី ម្ចាស់ ដី ធំៗ និង អ្នក អភិវឌ្ឍន៍ ផ្សេង ទៀត ដើម្បី បង្កើន ទីផ្សារ ដីធ្លី និង លំនៅឋាន (សិក្សា លើ ទីផ្សារ ដីធ្លី)។



៨- ពង្រឹង គុណភាព លំហ បៃតង និង អត្តសញ្ញាណកម្ម នៃ ទីក្រុង-រាជធានី-ចតុមុខ ដោយ ថែរក្សា បាន នូវ ទន្លេ ៤ មុខ និង រៀបចំ ឱ្យ មាន ប្លង់មេ លំហ បៃតង ។






៩- កំណត់ មុខងារ និង ប្រភេទ តំបន់ អភិវឌ្ឍន៍ ក្រុង តំបន់ សម្រាប់ សាងសង់ អគារ ខ្ពស់ (Skyscrapers) តំបន់ អភិរក្ស ប្រវត្តិសាស្ត្រ តំបន់ ភូមិគ្រឹះ តំបន់ ផ្ទះល្វែង តំបន់ ផែ ស្ងួត ...) ដើម្បី បញ្ចៀស នូវ ផល ប៉ះពាល់ អវិជ្ជមាន នានា ដូចជា ៖ ការ បំពុល បរិយាកាស សំឡេង កកស្ទះ ចរាចរ ។ល។

១០-ពង្រឹង សមត្ថភាព សេដ្ឋកិច្ច ក្នុង វិស័យ សំណង់ វាយនភណ្ឌ ការ ចិញ្ចឹម សត្វ-ត្រី ការ ដាំ ដុះ ការ ដឹក ជញ្ជូន ទេសចរណ៍ និង វិស័យ ជា យុទ្ធសាស្ត្រ ផ្សេង ទៀត ។






**Project of Master Plan of Phnom Penh city-2020**
**General destination of Land use plan**




## គម្រោង បែងចែក តំបន់ ប្រភេទ ដីធ្លី សម្រាប់ អនាគត ២០២០

Les surfaces (452.30Km²)

- តំបន់ ទីក្រុង ប្រវត្តិសាស្ត្រ.................................................. ៤៧០ ហាត =១%
- តំបន់ ទីក្រុង ដែល បាន រៀបរយ(១៩៥០)............................ ២.០០០ ហាត =៤.៤%
- តំបន់ ជាយក្រុង........................................................ ៦.២០០ ហាត =១៣.៧%
- តំបន់ សកម្មភាព សេដ្ឋកិច្ច-ឧស្សាហកម្ម............................ ៣.០០០ ហាត =៦.៦%
- តំបន់ ពង្រីក លំនៅឋាន................................................ ៣.៨០០ ហាត =១៩.៥%
- ទីប្រជុំជន បន្ទាប់ និង តំបន់ អភិវឌ្ឍន៍ ពិសេស..................... ១.១០០ ហាត =២.៤%
- តំបន់ សម្រាប់ រៀបចំ ប្រព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធ និង ស្ថានីយ.......... ៩០០ ហាត =១.៩%
- តំបន់ បម្រុង សម្រាប់ សំណង់ និង បរិក្ខារ សាធារណៈ-រដ្ឋបាល...... ២៣០ ហាត =០.៥%
- តំបន់ ភូមិម្គុរ ប្រជាជន និង តំបន់ សំណង់ ដង់ស៊ីតេ ទាប...... ៦.០០០ ហាត =១៣.២%
- តំបន់ បៃតង និង កម្សាន្ត................................................ ៤.៧០០ ហាត =១០.៤%
- តំបន់ កសិកម្ម ជាយក្រុង...................................................១០.០០០ ហាត =២២%
- តំបន់ ថៃរក្សា ធម្មជាតិ...................................................... ១.៤០០ ហាត =៣%
- តំបន់ អាង សម្រាប់ ច្រោះ ទឹក សំអុយ........................................... ៤៣០ ហាត =១%

© 2009, Phnom Penh Municipality, #69, Monivong Blvd, Sangkat Sras Chok, Khan Daun Penh, Phnom Penh, Cambodia. Alright Reserve.

**Source URL:** http://www.phnompenh.gov.kh/phnompenh/?q=km/node/51